## ១-មនុស្សកើតខែធ្នូ

នរជនប្រុស-ស្រីកើតខែធ្នូ(មិគសិរ)ច្រើនមានពណ៌សំបុរកាយដំដែង រាងស្រាវបន្តិច ជាមនុស្សធុនមធ្យម គឺមិន ក្រពេក មិនមានពេក ល្មមគ្រាន់តែចិញ្ចឹមអាត្មា ព្រមទាំងគ្រួសារបាន ថាបើសមាគមគប់មិត្តភក្តិ គប្បីជ្រើសយកមនុស្ស សំបូរប្រដំប្រសងនិងអាត្មាខ្លួន ទើបបានស្និទ្ធស្នាលអស់កាលអង្វែង ក្នុងចំណោមពួកនេះ បើមានកូនស្រីមុននោះមិននាំមក នូវសុខសួស្តីទេ មានតែសេចក្តីក្តៅក្រហាយរឿយៗ ផ្ទុយទៅវិញ កូនដែលប្រកបទៅដោយសេចក្តីសុខចំរើនត្រូវមានភេទ ជាប្រុស (សម្រាប់កូនដំបូង)បច្ចាមិត្តជាមួយនឹងមនុស្សដែលមានលក្ខណៈជាប្រុសភ្នែកលឿងជ្រៅ សក់រួញអង្គារដី បើ ភេទស្រីវិញ អ្នកនោះឯងដោះយាវម្ខាង គូគ្រងសម្រាប់ជនជំពូកនេះច្រើនជាមនុស្សចិត្តអាក្រក់ ឬព្រហើន សម្តីច្រើន ឈ្លើយ ពោលពាក្យគ្មានសុជីវធម៌ឡើយ ។

## ២-មនុស្សកើតខែមករា

នរជនប្រុស-ស្រីកើតខែមករា(បុស្ស)ដោយច្រើនមានពណ៌សំបុរកាយស លឿង ទើបត្រូវនឹងស្នេហ៍របស់អាត្មា ជាមនុស្សធុនមធ្យមគ្រប់គ្រាន់ចិញ្ចឹមខ្លួន ព្រមទាំងគ្រួសារ ថាបើសមាគមគប់រកមនុសស្សជាមិត្ត សមសួនគប្បីជ្រើសរើស យកអ្នកណាមានភេទជាប្រុស រូបរាងស្តើង កំពស់ស្រាវបន្តិច ទើបជាកល្យាណមិត្ត មានសន្តានចិត្តជួយបំពេញផលប្រ យោជន៏ឥតវៀចវេរ ប្រសិនណាជននេះមានកូនស្រីដំបូង កូននោះច្រើនរឹងរុះ ឬនាំមកនូវសេចក្តីព្រួយខានជាដរាបដល់ អាត្មា ផ្ទុយទៅវិញ បើកូនប្រុសដំបូង កូននោះនឹងបានជួយរំដោះសេចក្តីនឿយសព្រួយដែលមានផ្ទាល់អាត្មា ឬថានឹងបានស៊ី ពោះលោះកម្លាំងទៅគ្រាណាដែលជាកាលគួរបច្ចាមិត្តចំពោះ គឺមនុស្សសំបុរដំដែងភេទប្រុស បើស្រីវិញជាមនុស្សសំបូរស ជ្រះ រាងខ្ពស់បន្តិច សម្រាប់គូរវាសនាត្រូវបានគូរូបស្អាតសមរម្យ ហើយគូរនោះពិតជាមនុស្សគួរឱ្យកក់ក្តៅសង្ឃឹមបាន សព្វបែប ។

## ៣-មនុស្សកើតខែកុម្ភៈ

នរជនប្រុស-ស្រីកើតខែកុម្ភៈ(មាឃ)ច្រើនតែសំបុរកាយដំដែងជាមនុស្សធុនមធ្យម តែបើបានអប់រំហ្វឹកហ្វឺនឱ្យ ជំនាញខាងវិជ្ជាជីវៈនឹងបានជាមនុស្សសំបូរសប្បាយពេញទី បើសមាគមគប់មិត្តឱ្យបានប្រាកដប្រជា ត្រូវយកបុគ្គលមាន លក្ខណៈសប្បុរស ទើបបានសុខចំរើន បានបុត្រមានចិត្តអង់អាចក្លាហាន ចូលបំរើអ្នកធំបានគាប់ណាស់ មនុស្សជាបច្ចាមិត្ត ចំពោះជនពួកនេះច្រើនមានដោយការចងគំនុំ គួរតែប្រយ័ត្នខ្លួនឱ្យបានជិតដល់ ឬជាសត្រូវកើតឡើងមិនចំពោះក៏ថាបាន ចំណែកគូវាសនាត្រូវជួបជាមួយគូមានវង្សត្រកូលខ្ពស់សម្បើមទៅដោយកិត្តិយស ប៉ុន្តែសន្តានចិត្តរវាងពីគ្នា អធ្យាស្រ័យ បែកផ្លូវគ្នា ហើយមិនសូវគោរពគ្នាទៅវិញទៅមក ។

## ៤-មនុស្សកើតខែមីនា

នរជនប្រុស-ស្រីកើតខែមីនា(ផល្គុន)ច្រើនតែមានពណ៌សំបុរកាយ២ពណ៌ ជាមនុស្សថ្នាក់មធ្យម ប្រសិនបើមាន សមាគមគប់រកយកអ្នកណាធ្វើជាមិត្ត លុះត្រាតែអ្នកនោះមានសំបុរសលឿង ទើបមានចិត្តភក្តីភាពអស់អញ្ជលំគេញនិង អត្តា ពេលណាក៏ដូចជាពេលណា តាមពិតនរជនជំពូកនេះ បើបានអប់រំខ្លួនឱ្យល្អ ច្រើនមានបុណ្យវាសនាខ្ពស់ដោយសារការ ព្យាយាម និងសេចក្តីប្រព្រឹត្តរបស់ខ្លួន បានបុត្រមានសន្តានចិត្តល្អក្លាហាន តែលុះណាបុត្រនោះប្រុស ហើតកើតនាដើមឆ្នាំ ផង

ថាបើបានបុត្រស្រីដំបូងវិញច្រើនតែមានការរំជួលចិត្តទុក្ខជារឿយៗ បច្ចាមិត្តមានប្រចាំគឺមនុស្សស្រីតែម្យ៉ាង គូវាសនាសម្រាប់ជនពួកនេះ សម្តីមិនសូវត្រសោះអន្ទង ច្រើនពោលពាក្យអសុរស តែមានចិត្តគំនិតល្អ ឆ្លាតក្នុងការស្វែងរកសម្បត្តិ ។

## ៥-មនុស្សកើតខែមេសា

នរជនប្រុស-ស្រីកើតខែមេសា(ចេត្រ) បើតាមស្លោកថា មានពណ៌សំបុរកាយស្ទើរដំដែង មានអ្នកជួយឧបត្ថម្ភឱ្យ បានជាធំជាមនុស្សល្អត្រឹមត្រូវ កល្យាណមិត្តគឺមនុស្សសំបុរប្រហែលនឹងអ្នកម្ចាស់ជាតា រាងក្រអឹត ជំហរប្រឹង ថាបើបានកូនស្រីដំបូងទើបបានសុខចំរើន នាំមកនូវសុភមង្គលគ្រប់ប្រការ ផ្ទុយទៅវិញ បើកូនប្រុសដំបូងនោះ មុខជាមានតែការ រង្កៀសចិត្តព្រួយជានិច្ចដោយហេតុផ្សេងៗ តាមការពិត នរជនពួកនេះមានបច្ចាមិត្តយ៉ាងចំពោះ គឺមនុស្សសក់ទង់ដែងបះ ចុង ភ្នែកលឿងមុខឆ្អឹង សំបុរខ្មៅ ចំណែកគូវាសនាត្រូវបានជួបនឹងអ្នកមានសម្តីអាក្រក់ ពោលថាមិនគិតមុខក្រោយ ។

## ៦-មនុស្សកើតខែឧសភា

នរជនប្រុស-ស្រីកើតខែឧសភា(ពិសាខ) តាមស្លោកថាមានពណ៌សំបុរកាយ ស លឿង រាងខ្ពង់បន្តិច ជើងតូចសម្តីមិនចេះថ្នាក់ថ្នមពាក្យ ពេលណាក៏ដូចជាពេលណា មានតែពាក្យខ្លាំងៗវិញ មិត្តសំឡាញ់សំបូរតែមិត្តប្រចុកប្រសុី ឬមិត្ត ទ្រុស្តមិត្ត ។ ថាបើបានកូនប្រុសដំបូង កូននោះអាចដឹងគុណូបការៈ ជួយផ្តល់សេចក្តីចំរើនរឿយៗ ផ្ទុយទៅវិញ បើកូនដំបូង ស្រីច្រើនកើតក្តីក្តៅក្រហាយញឹកញយ សត្រូវប្រចាំការគឺមនុស្សស ក្រហម មានស្លាកស្នាមនៅមុខ រាងក្រអាញផងចំណែកគូវាសនាពិតប្រាកដ គឺមនុស្សមានសន្តានចិត្តប្រកបដោយធម៌ មានសទ្ធាទន់ជ្រាយបន្តិច ចូលចិត្តធ្វើបុណ្យទាន ណាស់ ។

## ៧-មនុស្សកើតខែមិថុនា

នរជនប្រុស-ស្រីកើតខែមិថុនា(ជេស្ឋ)បើយកត្រូវតាមស្លោក ត្រូវមានពណ៌សំបុរកាយខ្មៅ រាងខ្ពស់ ដំណើរកេង កាងជាមនុស្សបន្ទាប់បន្ទំ ចិញ្ចឹមអាត្មាបានស្រួល បើសមាគមគប់មិត្តគួរជ្រើសយកមនុស្សសំបុរត្រដំត្រសងនឹងខ្លួន ទើប បានជាមេត្រីមានភាតរភាពល្អ តាមពិតនរជនពួកនេះ បើបានកូនប្រុសដំបូងកូននោះអាចបានជាទីពឹងពំនាក់ទៅអនាគត ផ្ទុយទៅវិញបើបែរជាបានកូនស្រីច្បងច្រើនមានការផុលរមាស់ពុំស្រួលរឿយៗ បច្ចាមិត្តសម្រាប់ជនពួកនេះ គឺមនុស្សស្តើង រុយៗ ភ្នែកលឿងហើយគ្រលីបផង ចំណែកគូសម្រស់ ត្រូវបានជួបគូដែលវាទន់ភ្លន់ ឬកសុភាព ចិត្តសប្បុរស ល្មមទីពឹង សង្ឃឹមបានទៅវិញទៅមក ។

## ៨-មនុស្សកើតខែកក្កដា

នរជនប្រុស-ស្រីកើតខែកក្កដា(អាសាធ) បើយោងទៅតាមស្លោកថា មានពណ៌សំបុរកាយដំដែង រូបផាន់រាងស្តើងស្រាវបន្តិច ជាមនុស្សថ្នាក់កណ្តាល (ដែលទាប ឬ ខ្ពស់ ពិសេសទៅទៀតមានការទាក់ទងនឹងឫក្ស) ថាបើចង សមាគមគប់មិត្តគួរជ្រើសយកមនុស្សសំបុរដំដែងទើបបានជាកល្យាណមិត្ត មានភក្តីភាពរវាងគ្នានិងគ្នា ។ ចំពោះកូន បើ បានកូនប្រុសមុនមានសេចក្តីសុខសាន្ត នាំមកនូវចំរើនរឿយៗ ផ្ទុយទៅវិញ បើបានកូនស្រីដំបូង ច្រើនមានសេចក្តីព្រួយ រំខាន ខកចិត្តជាការធម្មតាបច្ចាមិត្តផ្ទាល់ភេទប្រុស មានលក្ខណៈសក់រួញអង្គាររដី ភ្នែកលឿង បើស្រីដោះសណ្តាយ គូគ្រងត្រូវបានលើមនុស្សចិត្តព្រហ៊ើនកោងកាច សម្តីមិនប្រាកដប្រជា ហើយសំបូរពោលពាក្យរោយរាយ ។

## ៩-មនុស្សកើតខែសីហា

នរជនប្រុស-ស្រីកើតខែសីហា(ស្រាពណ៍)តាមស្លោកដៅចំពោះថា មានសំបុរកាយសល្បឿង រាងទ្រទាប់បន្ទិច ជាមនុស្សជាន់កណ្តាល ប្រកបកិច្ចការរកស៊ីចិញ្ចឹមអាត្មាជាមធ្យម មិត្តសំឡាញ់ដែលអាចជួយគ្នាទៅវិញទៅមកបានជាស្ថាពរ គឺមនុស្សនោះភេទប្រុស រាងស្តើងបន្តិច តាមពិតនរជនជំពូកនេះ បើបានកូនប្រុសដំបូង មានសេចក្តីសុខចំរើនរឿយៗ ប្រកបទៅដោយការឆ្លាតវៃបញ្ញារហ័ស បច្ចាមិត្តចំពោះមនុស្សសំបុរខ្មៅ រាងស្រាវ បើស្រីវិញសំបុរស រាងឆ្ពោ ចំណែកគូជីវិតត្រូវជួបគូដែលមានសង្ឃឹមទៅអនាគត ។

## ១០-មនុស្សកើតខែកញ្ញា

នរជនប្រុស-ស្រីកើតខែកញ្ញា (ភទ្របទ) បើងយោងតាមស្លោកថាមានពណ៌សំបុរកាយដំដែង ជាមនុស្សជាន់បុទុ ប្រកបកិច្ចការចិញ្ចឹមជីវិតបានជាកណ្តាលការ (ប្រើឫក្សជួយកម្លាំងផ្សំផងអាចជំរុញជីវភាពឱ្យធ្លាក់ឬឡើងខ្ពស់ជាងនេះ បាន) បើសមាគមគប់មិត្តគួរជ្រើសយកមនុស្សសំបុរស ទើបបានជាមិត្តមានប្រយោជន៍ ជួយយិតយោងដល់គ្នានិងគ្នាដរាប ដល់អវសាន ។ តាមពិត ជនជំពូកនេះបើមានកូនៗនោះមានចិត្តអង់អាច ចូលធ្វើការរាជការនិងបានជាទីពេញចិត្តនាយអ្នក ធំសត្រូវសម្រាប់បុគ្គលក្រុមនេះមានលក្ខណៈមិនប្រាកដ សំបូរទៅដោយគេប៉ងបៀតបៀន តែមិនអាចបំផ្លាញបានឡើយ គប្បីប្រុងប្រយ័ត្នខ្លួនគ្រប់កិច្ចកល គូគ្រងត្រូវបានជួបនឹងមនុស្សត្រកូលកាត់(កូនកាត់)ទឹកចិត្តច្រើនរវាតចែកផ្លូវគ្នាបន្តិច ។

## ១១-មនុស្សកើតខែតុលា

នរជនប្រុស-ស្រីកើតខែតុលា (អស្សុជ)យកត្រូវនឹងស្លោក គឺមានគឺមានពណ៌សំបុរកាយលាយ២ពណ៌ ។ ជាមនុស្សសំខាន់ចិញ្ចឹមជីវិតបានស្រួល មានបុណ្យព្រេងព្រោះសេចក្តីព្យាយាមរបស់ខ្លួន ។ ត្រូវសមាគមគប់មិត្តជាមួយនិងមនុស្សសំបុរដំដែង បានផលប្រយោជន៍ល្អ តាមពិតនរជនពួកនេះ បើមានកូនដំបូងប្រុស បានជាទីរាប់អានស្រឡាញ់ ពេញចិត្ត បើកូនស្រីដំបូង កូននោះច្រើនបង្កការក្តៅក្រហាយដល់ខ្លួនញឹកញយ ។ បច្ចាមិត្តរួម គឺជាមួយតែមនុស្សភេទស្រីច្រើនមានចិត្តឥច្ឆាឈ្នានីសមិនចេះអស់ហើយ គូគ្រងត្រូវបានសម្រស់នឹងមនុស្សសម្តីរឹងទទឹងទិស តែគំនិតប្រាជ្ញាមានច្រើនគិតការបានល្អ ។

## ១២-មនុស្សកើតខែវិច្ឆិកា

នរជនប្រុស-ស្រីកើតខែវិច្ឆិកា (កត្តិក) បើតាមស្លោកថា : មានពណ៌សំបុរកាយដំដែង ។ ជាមនុស្សសំខាន់ម្នាក់ឬ បានជាធំព្រោះមានគេជួយឧបត្ថម្ភ បើសមាគមគប់មិត្តគួរជ្រើសរើសរកមនុស្សមានលក្ខណៈសាច់សក្រហម រាងក្រអឺត បន្តិចទើបបានមានស្នេហភាពនិងភក្តីដល់គ្នានិងគ្នាជាអចិន្ត្រៃយ៍ ។ តាមពិតនរជនពួកនេះ បើបានកូនស្រីដំបូងនឹងមានសេចក្តីចំរើនរុងរឿងគ្រប់ប្រការ ផ្ទុយទៅវិញ បើបានកូនប្រុសដំបូង រមែងមានសេចក្តីចង្អៀតចង្អល់ ព្រួយបារម្ភរឿយៗ បច្ចាមិត្តចំពោះខ្លួន គឺមនុស្សសក់រួញងរចុងខ្វង់ៗ ភ្នែកលឿង គូគ្រងត្រូវបានជួបនឹងគូរមានសម្តីត្រគោះបោះបោក និយាយខ្វះ សុជីវធម៌ ។